សំភារៈ ដែលកសិករអាចប្រើប្រាស់ ដើម្បីសង់ទ្រុង ឬ របងចានរួមមាន :

- ឫស្សី
- ធាងត្នោត
- ស្លឹកត្នោត
- សំណាញ់
- ជំនឿក្រណាត់ពីរោងចក្រ និង ខ្សែ (យកមកត្បាញធ្វើជាសំណាញ់)
- ធាងដូង
- កូនឈើ
- ដែកគោល
- ខ្សែលួស
- រុក្ខជាតិមួយចំនួន ដូចជា កន្ទំថែត ដំឡូងមី ស្នំ ថ្នើមអណ្តើក

គេក៏អាចប្រើសំភារៈខាងលើនេះរួមផ្សំគ្នាផងដែរ ឧទាហរណ៍ អាចយកឫស្សី ឬ ធាងត្នោតមកធ្វើជាជញ្ជាំង និង ស្លឹកត្នោតមកធ្វើជាដំបូល។

របងរស់ (របងអំពីដើមកន្ទំថែត ដំឡូងមី ស្នំ និង ថ្នើមអណ្តើក) ក៏អាចមានប្រយោជន៍ផងដែរ ព្រោះរុក្ខជាតិទាំងនេះ អាចផ្តល់ជាម្ហូប និង ចំណីអាហារដល់មាន់ទាផងដែរ។

សូមទំនាក់ទំនងលេខទូរស័ព្ទបន្ទាន់ខាងក្រោមនេះ នៅពេលប្រទះឃើញមាន់ទាងាប់ ហើយសង្ស័យថាជាករណីជំងឺផ្តាសាយបក្សី។

ដើម្បីកម្ពុជា ក្លាន់ជំងឺផ្តាសាយបក្សី

មានប្រជាពលរដ្ឋនៅកម្ពុជាជាច្រើននាក់ ដែលចិញ្ចឹមមាន់ទា នៅក្នុងទីធ្លាផ្ទះរបស់ពួកគេ។ ប្រជាពលរដ្ឋជាច្រើនគ្រាន់តែមានមាន់ ឬ ទា តែពីរបីក្បាល សំរាប់ការប្រើប្រាស់នៅក្នុងគ្រួសារតែប៉ុណ្ណោះ។ ការស្រាវជ្រាវបានបង្ហាញថា ប្រជាពលរដ្ឋមានការយល់ដឹងយ៉ាងច្រើន អំពីគ្រោះថ្នាក់នៃជំងឺផ្តាសាយបក្សី ហើយពួកគេចង់ទទួលបានព័ត៌មានបន្ថែមអំពីរបៀបការពារមាន់ទា និង គ្រួសាររបស់ពួកគេ អំពីជំងឺផ្តាសាយបក្សី។

បើសង្ស័យថាមានជំងឺផ្តាសាយបក្សីលើ**សត្វ** ឬ ចង់ល់នានា សូមទាក់ទងភ្នាក់ងារសុខភាពសត្វភូមិ ឬ មេភូមិ ឬ ទូរស័ព្ទមកលេខ : ០១២ ២១៤ ៩៧០ - ០១២ ៨៣៣ ៧៩៥

បើសង្ស័យថាមានជំងឺផ្តាសាយបក្សីលើ**មនុស្ស** ឬ ចង់ល់នានា សូមទាក់ទងភ្នាក់ងារសុខភាពភូមិ ឬ មេភូមិ ឬ ទូរស័ព្ទមកលេខ : ០១២ ៤៨៨ ៩៨១ - ០១២ ៨៣៦ ៨៦៨

USAID FROM THE AMERICAN PEOPLE

វិធានការបង្ការដែលសំខាន់ជាងគេបំផុត ដើម្បីបង្ការការឆ្លងជំងឺផ្តាសាយបក្សីគឺ :

- ដាក់មាន់ទានៅក្នុងទ្រុង ឬ របង (ទុកមាន់ទាទាំងនោះ អោយនៅដាច់ដោយឡែកពីមាន់ទាដទៃទៀត ដែលអាចឆ្លងជំងឺ)
- ទុកមាន់ទាចាស់ និង ថ្មីអោយនៅដោយឡែកពីគ្នារយៈពេល ១៤ ថ្ងៃ (ប្រសិនបើមាន់ទាមានឆ្លងជំងឺ វានឹងបញ្ចេញ អោយដឹងក្នុងរយៈពេល ១៤ ថ្ងៃ) ហើយ ធានាអោយ បានច្បាស់ថា មាន់ទាថ្មីចេញពីប្រភពគ្មានជំងឺផ្តាសាយបក្សី
- លាងដៃរបស់អ្នកជាមួយនឹងសាប៊ូមុន និងក្រោយពេល ប៉ះពាល់ជាមួយមាន់ទា (មេរោគអាច "ឆ្លង" ពីមាន់ទា មួយតាមរយៈមនុស្សម្នាក់ឆ្លងទៅកាន់ មាន់ ឬ ទា ផ្សេងទៀត)
- សំអាតលាមកពីទីធ្លាផ្ទះរបស់អ្នក ព្រោះមេរោគ ផ្តាសាយបក្សី អាចរស់នៅក្នុងលាមកបាន
- ទុកមាន់ អោយនៅដាច់ដោយឡែកពីទា (មាន់អាច ស្លាប់ភ្លាមពេលឆ្លងមេរោគផ្តាសាយបក្សី ប៉ុន្តែទាវិញ អាចមើលទៅនៅតែមានសុខភាពល្អ បើទោះបីជាវាមាន ឆ្លងជំងឺក៏ដោយ។ មាន់ទា ដែលឆ្លងជំងឺអាចចំលងមេរោគ ទៅអោយមាន់ទាផ្សេងទៀត និង មនុស្សបាន។)

ដើម្បីការពារមាន់ទារបស់អ្នកមិនអោយឆ្លងជំងឺ ផ្តាសាយបក្សី សូមប្រើប្រាស់វិធីមួយក្នុង ចំណោមវិធីទាំងបីខាងក្រោមនេះ :

របង:

ធ្វើរបងជុំវិញទីធ្លាផ្ទះដើម្បីបង្ខាំងមាន់ទារបស់អ្នក អោយនៅដោយឡែកពីមាន់ទាផ្សេងទៀតរបស់អ្នកជិតខាង ហើយនៅតែអាចមានធ្លាសំរាប់អោយមាន់ទារបស់អ្នកដើរ ស្វែងរកចំណីបាន។

ទ្រុងមាន់ទា:

ដាក់មាន់ក្នុងទ្រុង ឬ បង្ខាំងទាក្នុងរបងបិទជិត ។

អង្រុត:

ដាក់មាន់ទាក្នុងអង្រុត ។

មានតែខ្លួនអ្នកទេដែលអាចបង្ការជំងឺផ្តាសាយបក្សី